ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា
សាលា អ៊ីលីហ្សា ប. ឃើយប្រាយដ៍ ២០២០-២១

# ច្បាប់នៃការប្រើកាមេរ៉ា ក្នុងការសិក្សាតាមកុំព្យូទ័រ របស់សាលា ឃើយប្រាយដ៍ ឆ្នាំសិក្សា ២០២០-២០២១

ការប្រើការប្រជុំតាមវីដេអូគឺជាគំរូថ្មីរបស់យើងសម្រាប់ ការបង្ហាត់បង្រៀន និង ការសិក្សា។ វិធីថ្មីនេះតម្រូវឱ្យមាន គោលការណ៍ និង ច្បាប់ ថ្មីៗ។ យើងបានដឹងថាបទដ្ឋាននៃក្រមសីលធម៌ថ្មីៗទាំងនេះ អាចនាំមកនូវ ការព្រួយបារម្ភ និង/ឬ ភាពតានតឹង ដល់ក្រុមគ្រួសាររបស់យើង។ អ្នកគ្រប់គ្រង និង បុគ្គលិក របស់សាលា ឃើយប្រាយដ៍ នឹងខិតខំឱ្យអស់ពីសមត្ថភាពដើម្បីដោះស្រាយ កង្វល់/ភាពតានតឹង ទាំងងនេះ ដើម្បីឱ្យសិស្សានុសិស្សទាំងអស់ ចូលរួមក្នុងដំណើរការសិក្សា និង អាចទទួលបាននូវការរីកចម្រើនក្នុងការសិក្សាប្រកបដោយអត្ថន័យ។

សិស្សានុសិស្សត្រូវបើកកាមេរ៉ារបស់ពួកគេនៅក្នុងអំឡុងពេលនៃវគ្គសិក្សាតាម ហ្សូម ជាមួយលោកគ្រូអ្នកគ្រូរបស់ពួកគេ។ ការដែលអាចមើលសិស្សឃើញក្នុងពេលសិក្សា នឹងធានាបាននូវកត្តាជោគជ័យ ដូចតទៅនេះ៖

- គ្រូអាចពិនិត្យមើលការយល់ដឹងរបស់សិស្សានុសិស្សបានយ៉ាងឆាប់រហ័ស ដោយប្រើសញ្ញាដែលមិនមែនជាពាក្យសំដី ដូចជាការលើកមេដៃ
- គ្រូអាចដាស់តឿនសិស្សឱ្យផ្តោតការយកចិត្តទុកដាក់ ឧទាហរណ៍ បើសិនជាសិស្សកំពុងបែកអារម្មណ៍ ដោយសារអ្វីមួយនៅពីក្រោយ គ្រូអាចធ្វើឱ្យសិស្សនោះចូលរួមមកវិញ ដោយការបង្វែរឥរិយាបទរបស់គាត់។
- ការដែលមើលឃើញមុខគ្នា អនុញ្ញាតឱ្យមានទំនាក់ទំនងជាមួយគ្នាកាន់តែច្រើន ដែលអាចជួយជំរុញដល់ការកសាងសហគមន៍ នៅពេលដែលយើងអាចមើលឃើញពីអារម្មណ៍ ហើយធ្វើការឆ្លើយយតបទៅតាមនោះ។

បញ្ជីខាងលើមិនទូលំទូលាយទេ។ មានមូលហេតុជាច្រើនទៀតដែលធ្វើឱ្យច្បាប់នៃការ «បើកកាមេរ៉ា» ផ្តល់អត្ថប្រយោជន៍ដល់ការអប់រំទាំងអស់។ សូមកត់សម្គាល់ថា យើងដឹងអំពីការព្រួយបារម្ភដ៏សមហេតុផលអំពីអ្វីដែលគេអាចមើលឃើញនៅពីក្រោយក្នុងខណៈពេលដែលកាមេរ៉ាបើក ហើយសិស្សមួយចំនួនស្ទាក់ស្ទើរក្នុងការអនុញ្ញាតឱ្យអ្នកដ៏ទៃចូលក្នុងបរិវេណរបស់ខ្លួន។ ដើម្បីដោះស្រាយបញ្ហានេះ យើងសុំឱ្យសិស្សានុសិស្សបង្កើតរូបនិម្មិតនៃរូបភាពពីក្រោយ (virtual background)។ យើងក៏ដឹងដែរថា ការសិក្សាពីផ្ទះ នាំឱ្យបែកអារម្មណ៍បន្ថែមទៀត។ យើងសុំឱ្យសិស្សម្នាក់ៗ ខិតខំឱ្យអស់ពីសមត្ថភាពដើម្បីរកទីកន្លែងណាមួយនៅក្នុងផ្ទះ ដែលគ្មាន សម្លេង និង អ្វីៗ ដែលនាំឱ្យរំខាន នៅពីក្រោយ។

យើងក៏ទទួលស្គាល់ផងដែរថា ការមើលខុសត្រូវតាមកុំព្យូទ័រ មិនអាចមើលបានជិតដល់ដូចការមើលខុសត្រូវដោយផ្ទាល់នោះទេ។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីធានាបាននូវ ការបង្ហាត់បង្រៀន និង ការរៀនសូត្រ ដោយជោគជ័យ យើងនៅតែតម្រូវឱ្យសិស្សសុំការអនុញ្ញាត នៅពេលណាដែលគាត់ចង់ចាកចេញពីមុខកុំព្យូទ័រ។

**បេសកកម្មរបស់យើង៖ ១០០% នៃសិស្សានុសិស្ស នឹងទទួលការឱ្យចូលរៀននៅវិទ្យាល័យដែលពួកគេបានជ្រើសរើស!**

ឧទាហរណ៍ បើសិនជាសិស្សត្រូវការប្រើបន្ទប់ទឹក សិស្សត្រូវផ្ញើសារជាឯកជនទៅគ្រូ នៅក្នុងប្រអប់សរសេរឆ្លងឆ្លើយ (chat box) ដើម្បីឱ្យគាត់ដឹងថាកាមេរ៉ានឹងត្រូវបិទ**មួយភ្លែត** ដើម្បីដោះស្រាយតម្រូវការ**ចាំបាច់**នៅផ្ទះ។ វិធីនេះមិនគប្បីប្រើញឹកញាប់ទេ។ ការចង់បាន គឺត្រូវបើកកាមេរ៉ា ហើយសិស្សានុសិស្សត្រូវចូលរួមរៀនមេរៀនក្នុងរយៈពេលទាំងមូលនៃវគ្គបង្រៀនតាមហ្សូម។ លើសពីនេះទៀត អាចមានពេលខ្លះ នៅពេលណាដែលសមស្របទៅនឹងការបង្ហាត់បង្រៀន គ្រូអាចប្រាប់ឱ្យសិស្សានុសិស្សបិទកាមេរ៉ារបស់ពួកគេ សម្រាប់ផ្នែកណាមួយជាក់លាក់នៃមេរៀន។ ការចង់បានរបស់យើង គឺឱ្យសិស្សានុសិស្សធ្វើតាមការណែនាំរបស់គ្រូ អំពីការប្រើប្រាស់កាមេរ៉ា ហើយបន្ទាប់មកបើកកាមេរ៉ារបស់ពួកគេវិញ នៅពេលមានការណែនាំឱ្យធ្វើដូច្នោះ។ បើសិនជាកាមេរ៉ារបស់សិស្សមិនដើរ សិស្សត្រូវប្រាប់ឱ្យគ្រូដឹងនៅពេលចាប់ផ្តើមបង្រៀន តាមរយៈប្រអប់សរសេរសារឆ្លងឆ្លើយ។ គ្រូអាចជួយដល់ សិស្ស និង ក្រុមគ្រួសារ តាមវិធីដើម្បីផ្លាស់ប្តូរកុំព្យូទ័រក្រូមប៊ុក។

ការភ្ជាប់ទំនាក់ទំនងជាមួយសិស្សានុសិស្សរបស់យើង គឺជាកត្តាជំរុញដ៏សំខាន់មួយនៃជោគជ័យក្នុងការបង្ហាត់បង្រៀនតាមកុំព្យូទ័រ ហើយច្បាប់នេះអនុញ្ញាតឱ្យលោកគ្រូអ្នកគ្រូរបស់យើង ភ្ជាប់ និង ស្វែងយល់ កាន់តែច្បាស់ពីសេចក្តីត្រូវការរបស់សិស្សានុសិស្សរបស់យើង ក៏ដូចជាវិធីដើម្បីជួយដល់ពួកគាត់។ បើសិនជាលោកអ្នកមានសំណួរ ឬ បារម្ភ អ្វីអំពីច្បាប់នេះ សូមទាក់ទងមកអ្នករដ្ឋបាល។

**បេសកកម្មរបស់យើង៖ ១០០% នៃសិស្សានុសិស្ស នឹងទទួលការឱ្យចូលរៀននៅវិទ្យាល័យដែលពួកគេបានជ្រើសរើស!**